**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :..................៤៤៨..................**ក.ប**/ប្រក.ប.ស.ស

# ប្រកាស
# ស្តីពី
# បញ្ញើការសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ ._**

ប្រកាសនេះមានគោលបំណងចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព។

**ប្រការ ២ ._**

ប្រកាសនេះមានគោលដៅកំណត់បែបបទ និងនីតិវិធី នៃការចុះបញ្ជិកាសហគ្រាស គ្រឹះ ស្ថាន និងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ។

**ប្រការ ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ៤ ._**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម ៖

- ***សហគ្រាស*** សំដៅដល់សហគ្រាស ឬគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវាកម្ម កសិកម្ម សិប្បកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាបង្រៀនវិជ្ជាជីវៈឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈ សេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ ។ សហគ្រាសអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗ

មានប្រើមនុស្សឱ្យធ្វើការងារក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាងការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំរបស់និយោជក ។ គ្រឹះស្ថានស្ថិតនៅក្រោមឱវាទសហគ្រាសមួយជានិច្ច ។ គ្រឹះស្ថានអាចមានប្រើមនុស្សតែម្នាក់ក៏បានដែរ ។ ករណីគ្រឹះស្ថាននេះមានតែមួយឯកឯង និងមិននៅក្រោមសហគ្រាសណាទេ គ្រឹះស្ថាននោះត្រូវចាត់ទុកជាសហគ្រាស ។

- ***និយោជក*** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ជាសាធារណៈ ឬឯកជន ដែលប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាកម្មករនិយោជិតជាប់លាប់ ឬម្តងម្កាល ។
- ***កម្មករនិយោជិត*** សំដៅដល់ជនគ្រប់ភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យា យកកំរៃជាសាធារណៈ ឬឯកជន ។ លក្ខណៈសម្បត្តិនៃកម្មករនិយោជិត មិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តនៃនិយោជក ឬលក្ខន្តិកៈគតិយុត្តនៃកម្មករនិយោជិត ព្រមទាំងមិនត្រូវគិតពីប្រាក់ឈ្នួលតិច ឬច្រើន ។

## ជំពូកទី ២
## ការចុះបញ្ជី
## ផ្នែកទី១
## ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

**ប្រការ ៥ .-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលនៅក្នុងដែនអនុវត្ត នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួន នៅបេឡាជាតិរបបសន្តិសុខសង្គម ។

រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ ៖

- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ក្រោយពីប្រកាសនេះចូលជាធរមាន ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថាន ។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព រួចហើយ មិនមានកាតព្វកិច្ចក្នុងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ឡើងវិញទេ ។

**ប្រការ ៦ .-**

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតូបករណ៍គតិយុត្តសមមូលដទៃទៀត ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិតក្នុងពេលដំណាលគ្នានិងទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចជូនដំណឹងមក ប.ស.ស ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីមានការព្យួរ បិទ ឬ ផ្អាកសកម្មភាពអាជីវកម្ម ការប្តូរនិយោជក ឬម្ចាស់សហគ្រាស ឬអ្នកតំណាង អាសយដ្ឋាន ឬនាមករណ៍សហគ្រាស ។

## ផ្នែកទី ២
## ការចុះបញ្ជីកម្មករនិយោជិត

**ប្រការ ៧ .-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងយូររយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទអនុញ្ញាតឱ្យចូលធ្វើការ លើកលែងតែកម្មករនិយោជិតដែលមានប័ណ្ណសមាជិក ប.ស.ស រួចហើយ ។

**ប្រការ ៨ .-**

នីតិវិធី និងបែបបទនៃការចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវធ្វើតាមទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត ឬហៅថាទម្រង់ "១.០២" ដែលមានចែងក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

ដើម្បីចុះបញ្ជីក្នុង ប.ស.ស កម្មករនិយោជិតសញ្ជាតិខ្មែរត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយឡែកចំពោះកម្មករនិយោជិតបរទេសត្រូវមានលិខិតឆ្លងដែន ។

## ផ្នែកទី ៣
## អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

**ប្រការ ៩ .-**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាន នីមួយៗ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ។ សហគ្រាស គ្រឹះស្ថាន

មួយត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ ដែលឱ្យឈ្មោះថា "លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" ។

បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច ។ វិញ្ញាបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និង កាលបរិច្ឆេទចុះបញ្ជិកា ។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន ។

**ប្រការ ១០ .-**

បន្ទាប់ពីបានទទួលទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត និងការកំណត់អត្តសញ្ញាណកម្មករនិយោជិតរួចហើយបេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់លេខអត្តសញ្ញាណកម្មករនិយោជិត និងចេញប័ណ្ណសមាជិក ប.ស.ស ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ ។ ប័ណ្ណសមាជិក ប.ស.ស ត្រូវប្រគល់ជូនកម្មករនិយោជិតតាមរយៈនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ។

ក្នុងករណីដែល "ប័ណ្ណសមាជិក ប.ស.ស" ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងត្រូវស្នើសុំទុតិយតា ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ ។ ការផ្តល់ប័ណ្ណទុតិយតាតម្រូវឱ្យសាមីជនបង់ប្រាក់ចំនួន **២,០០០ (ពីរពាន់) រៀល** ជូនទៅបេឡាជាតិរបបសន្តិសុខសង្គម ។

## ផ្នែកទី ៤
## របាយការណ៍កម្មករនិយោជិត

**ប្រការ ១១ .-**

រៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ។

របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍ ។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ដែលត្រូវផ្តល់ជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានភ្ជាប់លិខិតបញ្ជូន ចុះហត្ថលេខាដោយនិយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**ប្រការ ១២.-**

ជនដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទោសដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៣.-**

ប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ប្រកាសលេខ ២៨៥ ក.ប-ប្រ.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៤.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួងពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីអនុវត្ត"
- សមាគមនិយោជក និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ២. នៃប្រកាសលេខ:...៤៤៨...កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១.០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ៖ .............................

# សលាកប័ត្រព័ត៌មាន

# កម្មករនិយោជិត

លេខអត្តសញ្ញាណប.ស.ស

| | | | | | | | - | | | | | | | | - | |

## ក- ព័ត៌មានផ្ទាល់ខ្លួន

១- គោត្តនាម........................ នាម .................................. ជាអក្សរឡាតាំង ............................................................

២- ភេទ......... សញ្ជាតិ................... ថ្ងៃខែឆ្នាំកំណើត ......./........./.......... អត្តសញ្ញាណប័ណ្ណលេខ.................................

៣- ទីកន្លែងកំណើត ផ្ទះលេខ............. ផ្លូវ................... ភូមិ/ក្រុម............................ ឃុំ/សង្កាត់.........................................
ស្រុក/ខណ្ឌ/ក្រុង .......................................... ខេត្ត/រាជធានី ..............................................................................

៤- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ..............ផ្លូវ .................. ភូមិ/ក្រុម.......................... ឃុំ/សង្កាត់.....................................
ស្រុក/ខណ្ឌ/ក្រុង ...............................ខេត្ត/រាជធានី ..................................លេខទូរស័ព្ទ:......................................

## ខ- ព័ត៌មានការងារ

៥- ឈ្មោះសហគ្រាស.....................................................................លេខអត្តសញ្ញាណស.ហ.....................................

៦- លេខអត្តសញ្ញាណ ប.ស.ស ចាស់.............................................លេខអត្តសញ្ញាណ នៅស.ហ..................................

៧- មុខងារ ................................................... ប្រាក់ឈ្នួល ....................... កាលបរិច្ឆេទចូលធ្វើការ........./........./..........

## គ- ព័ត៌មានគ្រួសារ

៨- ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៩- ប្រពន្ធ ឬប្តីឈ្មោះ.................................................... សញ្ជាតិ...................... ថ្ងៃខែឆ្នាំកំណើត........./........./..........
មុខរបរសព្វថ្ងៃ ..........................................................................................................................................

១០-អំពីកូន...........នាក់

១. ឈ្មោះ .................................. ភេទ........ កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ .................................

២. ឈ្មោះ .................................. ភេទ........ កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ .................................

៣. ឈ្មោះ .................................. ភេទ........ កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ........... មុខរបរ .................................

| មេដៃខាងឆ្វេង | មេដៃខាងស្តាំ |
| --- | --- |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។

ធ្វើនៅ...............ថ្ងៃទី.......ខែ..........ឆ្នាំ២០...

**ហត្ថលេខា ឬស្នាមម្រាមដៃសាមីខ្លួន**

ធ្វើនៅ........... ថ្ងៃទី..........ខែ........... ឆ្នាំ២០...

**ហត្ថលេខា និង ឈ្មោះមន្ត្រីពិនិត្យ**

**ឯកសារភ្ជាប់**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន

ឧបសម្ព័ន្ធ ១. នៃប្រកាសលេខៈ.....២២៨.....ក.ប/ប្រ.ក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១.០១

# បញ្ជិកាសហគ្រាស គ្រឹះស្ថាន

| សម្រាប់មន្ត្រី ប.ស.ស |
|---|
| លេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថានៈ ☐☐☐☐☐☐☐☐ |
| ហត្ថលេខាៈ........................ / / |

១. ឈ្មោះសហគ្រាស គ្រឹះស្ថានៈ..................................................

ឈ្មោះជាអក្សរឡាតាំងៈ..................................................

២. អាសយដ្ឋានទីស្នាក់ការកណ្តាលៈអគារលេខ...........ផ្លូវ...........ឃុំ/សង្កាត់...........ស្រុក/ខណ្ឌ/ក្រុង...........រាជធានី/ខេត្ត...........

ទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐ ទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ...........................

៣. អាសយដ្ឋាននៃកន្លែងធ្វើការងារៈ អគារលេខ...........ផ្លូវ...........ឃុំ/សង្កាត់...........ស្រុក/ខណ្ឌ/ក្រុង...........រាជធានី/ខេត្ត...........

ទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐ ទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ...........................

(ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

៤. លេខបញ្ជិកាពាណិជ្ជកម្មៈ ☐☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថានៈ ☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស)**

កាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថានៈ........./.........../...........កាលបរិច្ឆេទមានកម្មករចាប់ពី ០១នាក់ ឡើងៈ.........../.........../...........

៥. ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានៈ..................................................ភេទៈ...........សញ្ជាតិៈ...........

ឈ្មោះជាអក្សរឡាតាំងៈ..................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខៈ..................................................

អាសយដ្ឋានអចិន្ត្រៃយ៍ៈអគារលេខ...........ផ្លូវ...........ឃុំ/សង្កាត់...........ស្រុក/ខណ្ឌ/ក្រុង...........រាជធានី/ខេត្ត...........

ទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐ ទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ...........................

៦. ឈ្មោះអ្នកគ្រប់គ្រង/អ្នកតំណាងនិយោជកៈ..................................................ភេទៈ...........សញ្ជាតិៈ...........

ឈ្មោះជាអក្សរឡាតាំងៈ..................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខៈ..................................................

អាសយដ្ឋានអចិន្ត្រៃយ៍ៈអគារលេខ...........ផ្លូវ...........ឃុំ/សង្កាត់...........ស្រុក/ខណ្ឌ/ក្រុង...........រាជធានី/ខេត្ត...........

ទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐ ទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ...........................

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន ។

...................ថ្ងៃទី...........ខែ...........ឆ្នាំ...........

**ហត្ថលេខា និងត្រានាយក**

ឯកសារត្រូវយកភ្ជាប់មកជាមួយៈ

- បញ្ជិកាពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- របាយការណ៍ប្រើប្រាស់កម្មករនិយោជិត
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាង